ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

ស្សាហកម្ម រ៉ែ និង ថាមពល

ndustry, Mines and Energy

...១៣.១៩៥..ឧក.ធរ.អប

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ សីហា ឆ្នាំ២០០៨

# អាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និង ការដ្ឋានវាយថ្ម

( សំរាប់ឆ្នាំទី២)

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រង និង ការធ្វើអាជីវកម្មធនធានរ៉ែ ។
- បានឃើញអនុក្រឹត្យលេខ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញលិខិតលេខ:១១១៤ ធទឧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ របស់ក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធានគណ:កម្មាធិការគ្រប់គ្រងធនធានខ្សាច់ ។
- បានឃើញកិច្ចព្រមព្រៀង ស្តីពីការធ្វើអាជីវកម្មខ្សាច់សំណង់ នៅតំបន់ទន្លេមេគង្គលើ ឃុំរការអារ ស្រុកកងមាស, ឃុំព្រែកពោធិ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម រវាង ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រុមហ៊ុន CHONG SAN OCEAN DEVELOPMENT Co., Ltd. ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៧ ។
- បានឃើញអាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្មលេខ ៧៥២ ឧរថ.ធរ.អប ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០៧ ។
- បានឃើញលិខិតស្នើសុំបន្តអាជ្ញាប័ណ្ណរបស់ក្រុមហ៊ុន CHONG SAN OCEAN DEVELOPMENT Co., Ltd. ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៨ ។

## សំរេច

ប្រការ១ : អនុញ្ញាតអោយក្រុមហ៊ុន CHONG SAN OCEAN DEVELOPMENT Co., Ltd. មានអាសយដ្ឋាន ផ្ទះលេខ១៨អ ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ធ្វើអាជីវកម្មខ្សាច់សំណង់ នៅតំបន់ទន្លេមេគង្គលើ ឃុំរការអារ ស្រុកកងមាស, ឃុំព្រែកពោធិ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម លើផ្ទៃដីសរុប ២,៣៦(ពីរគត់សញ្ញា សាមសិបប្រាំមួយ គីឡូម៉ែត្រក្រឡា) សំរាប់ផ្គត់ផ្គង់ក្នុងស្រុក

| ចំណុច | អាប់ស៊ីស | អ័រដោនេ | ចំណុច | អាប់ស៊ីស | អ័រដោនេ |
|---|---|---|---|---|---|
| A | 5 10 000 | 13 09 900 | C | 5 12 000 | 13 08 830 |
| B | 5 12 000 | 13 10 220 | D | 5 10 000 | 13 08 830 |

ប្រការ២ : ក្រុមហ៊ុន CHONG SAN OCEAN DEVELOPMENT Co., Ltd. ត្រូវដំណើរការអាជីវកម្មខ្សាច់សំណង់ នៅតំបន់ទន្លេមេគង្គលើ ឃុំរការអារ ស្រុកកងមាស, ឃុំព្រែកពោធិ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ទៅតាមទំហំផ្ទៃដីដែលបានកំណត់ ខាងលើ និង :

- រាយការណ៍ប្រចាំខែស្តីពីបរិមាណដែលផលិតបាន និង បង់សួយសារថ្លៃវត្ថុធាតុដើមខ្សាច់សំណង់នៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងកំឡុងពេលប្រាំពីរ(០៧)ថ្ងៃ នៅមុនរៀងរាល់ពេលដឹកខ្សាច់សំណង់ចេញពីការដ្ឋាន ។
- ធានាអនុវត្តតាមលក្ខណៈបច្ចេកទេសអាជីវកម្មរ៉ែ និង ធានាការពារបរិស្ថានអោយបានត្រឹមត្រូវតាមច្បាប់ ។
- បង់ពន្ធអាករផ្សេងៗទៀតទៅតាមច្បាប់ដែលមានជាធរមាន ។

ប្រការ៣ : ពេលជួបប្រទះរ៉ែផ្សេងៗត្រូវរាយការណ៍មកក្រសួងជាបន្ទាន់ ។ បើប្រព្រឹត្តល្មើស អាជ្ញាប័ណ្ណនេះនឹងត្រូវដកហូត និង មានការពិន័យទៅតាមច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ។

ប្រការ៤ : អាជ្ញាប័ណ្ណនេះមានសុពលភាពរហូតដល់ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០៩។ យ៉ាងហោចណាស់៣០ថ្ងៃ មុនផុតសុពលភាព នៃអាជ្ញាប័ណ្ណនេះ ក្រុមហ៊ុន CHONG SAN OCEAN DEVELOPMENT Co., Ltd. ត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណបន្តជាថ្មី ។

ប្រការ៥ : អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានរ៉ែ អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានរដ្ឋបាល និង ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្តកំពង់ចាម ក្រុមហ៊ុន CHONG SAN OCEAN DEVELOPMENT Co., Ltd. ត្រូវទទួលអនុវត្តអាជ្ញាប័ណ្ណនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ៦ : អាជ្ញាប័ណ្ណនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០៨ នេះតទៅ ។

រដ្ឋមន្ត្រី
ជ្ជ
ចូ និងហិរញ្ញវត្ថុ
ជ្ជកម្ម
កិវឌ្ឍន៍កម្ពុជា
រណៈការ និង ដឹកជញ្ជូន
ម្ម រុក្ខាប្រមាញ់ និងនេសាទ
រដែនដី នគរូបនីយកម្ម និង សំណង់
ន
ានទឹក និងឧតុនិយម
យ និងរដ្ឋាក
កំពង់ចាម

ស៊ុយ_សែម